ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
***

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ ទាយតម្លៃ និងស្រាវជ្រាវ

កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកញ្ញា ឆ្នាំ២០២២

១. សេចក្តីផ្តើម

នៅថ្ងៃចន្ទ ៨កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ ចាប់ពីម៉ោង ៣:០០នាទីរសៀល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ឯកឧត្តមទីប្រឹក្សា ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង នាយកខុទ្ទកាល័យ និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិបើកអង្គប្រជុំ និងបើកកម្មវិធីដោយ**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣) បទបង្ហាញ ស្តីពីការប្រើប្រាស់ទិន្នន័យ និងថាមវន្ត នៃអ្នកពាក់ព័ន្ធ (DSS) ដើម្បីសម្រេចបានគោលដៅគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ ដោយ**ឯកឧត្តមវេជ្ជ. ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤) អនុសាសន៍ណែនាំ ដោយឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើមនៃកិច្ចអង្គប្រជុំ ក្រោយមតិស្វាគមន៍បើកកិច្ចប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ដល់ថ្នាក់ដឹកនាំត្រូវគិតគូពីការរៀបចំគោលនយោបាយជាតិ សម្រាប់បញ្ចប់អេដស៍ នៅឆ្នាំ២០២៥ ដោយសារនិន្នាការនៃឆ្លងមេរោគអេដស៍ថ្មីនៅមិនទាន់មានការថយចុះទៅតាមការរំពឹងទុកនៅឡើយ។

ឯកឧត្តមបានបញ្ជាក់ថានៅពេលយើងអាចបញ្ចប់អេដស៍ហើយ យើងត្រូវធានានូវចីរភាពនៃកម្មវិធីឆ្លើយតបមេរោគអេដស៍ ដោយធ្វើយ៉ាងណាឱ្យមានការឆ្លងថ្មីមកត្រឹម ០១នាក់/ថ្ងៃ និងមានការស្លាប់នៅក្រោម៣នាក់/ថ្ងៃ។ ការងារបង្ការត្រូវតែបង្កើនសម្រាប់ក្រុមប្រជាជនទូទៅ ក្រុមប្រជាជនគន្លឹះ ក៏ដូចជាការទប់ស្កាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនផងដែរ។

នៅក្នុងបទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំ បានឆ្លុះបញ្ចាំងពីសកម្មភាព ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ក៏ដូចជាសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន និងផែនការសកម្មភាពបន្ទាប់សម្រាប់អគ្គលេខាធិការដ្ឋាន ដោយផ្តោតទៅលើការសម្រេចគោលដៅ ៩៥ ទី១ នៃគោលដៅ ៩៥-៩៥-៩៥។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងការកោតសរសើរដល់មន្ត្រីអគ្គលេខាធិការដ្ឋាន ចំពោះការខិតខំប្រឹងប្រែងធ្វើការងារកន្លងមក ក្នុងការសម្រេចការងារគួរជាទីពេញចិត្ត។ ឯកឧត្តមបានលើកទឹកចិត្តដល់អគ្គលេខាធិការដ្ឋាន សូមបន្តការងារក្នុងការបញ្ចប់ឯកសារ ការបង្ការការចម្លងមេរោគអេដស៍ជាសកល ឱ្យបានក្នុង ឆ្នាំ២០២២នេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ពីសរសេរស្តម្ភលើការងារបង្ការគឺមាន៥គឺ ១) គឺសកម្មភាពផ្តោតលើក្រុមប្រជាជនគន្លឹះ ២) សេវាបង្ការរួមបញ្ចូលគ្នាលើក្រុមយុវវ័យជានារី ៣) សេវាបង្ការរួមបញ្ចូលគ្នាសម្រាប់ពួកបុរស ៤) ការប្រើប្រាស់ស្រោមអនាម័យ ៥) ផ្តោតលើសេវាបង្ការផ្សេងៗទៀត PrEP, ...។

បទបង្ហាញរបស់**ឯកឧត្តមទា ផល** បានគូសបញ្ជាក់ថា បញ្ហាធំគឺកង្វះថវិកា ហើយក្រុមប្រជាជនគន្លឹះមិនមកទទួលសេវាបង្ការ ជាពិសេសក្រុមបុរសរួមភេទជាមួយបុស (MSM) គេចមិនព្រមទទួលសេវា និងមិនយល់ថាខ្លួនមានការប្រឈមនឹងការឆ្លងមេរោគអេដស៍ ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា តាមរយៈលិខិតឆ្លើយតបរបស់ក្រសួងសុខាភិបាល បានបង្ហាញឱ្យឃើញថាមានតែ១០.៤% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានទទួលបណ្ណសមធម៌ (ID Poor)។ តាមទិន្នន័យនេះអ្នកផ្ទុកមេរោគអេដស៍ទទួលបានបណ្ណសមធម៌នៅមានកម្រិតទាបនៅឡើយ។

៣. អនុសាសន៍ របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

១) **ឯកឧត្តម ទា ផលា ឯកឧត្តម រស់ សីលាត់ ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត** ត្រូវពិនិត្យផ្ទៀងផ្ទាត់ពីទិន្នន័យទាក់ទងនឹងក្រុមប្រជាជនគន្លឹះមានក្រុមស្ត្រីបំរើសេវាកម្សាន្តសប្បាយ ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីរៀបចំរបាយការណ៍ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។

២) **ឯកឧត្តមវេជ្ជ. ទា ផលា** ត្រូវសម្របសម្រួល កិច្ចប្រជុំមួយផ្តោតលើការងារបង្ការដើម្បីសម្រេចគោលដៅ ៩៥ ទី១ ដោយត្រូវគិតគូពីការវាយតម្លៃពីឧបសគ្គ និងការប្រឈម ក៏ដូចជាដំណោះស្រាយ។

៣) ត្រូវគិតគូពីការរៀបចំគោលនយោបាយបញ្ចប់អេដស៍ សម្រាប់អាណត្តិក្រោយ និងចីរភាពនៃការឆ្លើយតបអេដស៍នៅក្រោយ ឆ្នាំ២០២៥។

៤) ត្រូវបញ្ចប់ឯកសារ ស្តីពីការបង្ការមេរោគអេដស៍ជាសកល ដោយត្រូវបញ្ចប់ក្នុង ឆ្នាំ២០២២។

៥) ត្រូវមានការសាកសួរដល់ក្រសួងទាំងអស់ថាគាត់ត្រូវការអ្វីខ្លះ ឱ្យអាជ្ញាធរជាតិជួយដល់ពួកគាត់។

៦) ត្រូវមានការតាមដានការងារឆ្លើយតបមេរោគអេដស៍ នៅតាមបណ្តាខេត្តដែលមានថវិការួចហើយទាំងខេត្តបានទទួលថវិកា ៨០លានរៀល និង៦០លានរៀល។

៧) **ឯកឧត្តម ស៊ឹម គឹមសាន ឯកឧត្តម ជា ប៉ោ** សូមទទួលការងារសម្របសម្រួលរៀបចំការជួបជុំជាមួយក្រុមតារា និងសិល្បករ ដោយឯកឧត្តមទេសរដ្ឋមន្ត្រីនឹងអញ្ជើញចូលរួមសំណេះសំណាលៗ។

អង្គប្រជុំ បានបញ្ចប់នៅវេលាម៉ោង 5:00នាទី រសៀលថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងមានការចូលរួមយ៉ាងសកម្ម។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

អ្នកធ្វើកំណត់ហេតុ

លោកវេជ្ជ. ទេព ណារុង

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ

ឈៀ-ម៉ូលី